01614034

E466

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម **Claudia FENZ** |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម **យូរ ឧត្តរា** |
| កាលបរិច្ឆេទ | ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩ |
| ភាសាដើម | ខ្មែរ/អង់គ្លេស |
| ចំណាត់ថ្នាក់ឯកសារ | សាធារណៈ |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 05 / 04 / 2019
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

# ដីកាចាត់តាំងចៅក្រមបម្រុងជំនួសកន្លែងចៅក្រមពេញសិទ្ធិដែលបានលាលែងពីមុខដំណែង

---

**<u>សហព្រះរាជអាជ្ញា</u>**

ជា លាង
Nicholas KOUMJIAN

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ
Marie GUIRAUD

**<u>ជនជាប់ចោទ</u>**

នួន ជា
ខៀវ សំផន

**<u>មេធាវីការពារក្តី</u>**

សុន អរុណ
Doreen CHEN
គង់ សំអុន
Anta GUISSÉ

**យើង ចៅក្រម និល ណុន** ប្រធានអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

**បានឃើញ** ការលាលែងពីតំណែងរបស់ចៅក្រម Jean-Marc LAVERGNE ដែលចូលជាធរមាននៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩។

**រម្លឹកឡើងវិញ** នូវបទប្បញ្ញត្តិមាត្រា ១១ ថ្មី នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ និងវិធាន ៧៩(៤) នៃវិធានផ្ទៃក្នុង ដែលអនុញ្ញាតឱ្យប្រធានអង្គជំនុំជម្រះសាលាដំបូងចាត់តាំងចៅក្រមបម្រុងឱ្យជំនួសកន្លែងចៅក្រមពេញសិទ្ធិដែលអវត្តមានសម្រាប់បន្តកិច្ចដំណើរការនីតិវិធី ក្នុងករណីអវត្តមានចៅក្រមពេញសិទ្ធិណាម្នាក់ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយចៅក្រមដទៃទៀត។

**យល់ឃើញថា** បញ្ហានានាអាចនឹងកើតមានជាបន្តទៀត ក្នុងសំណុំរឿង ០០២/០២ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដែលតម្រូវឱ្យមានការពិចារណាដោយអង្គជំនុំជម្រះដែលមានសមាសភាពចៅក្រមពេញលេញ។

**បន្ទាប់ពីបាន** ពិគ្រោះយោបល់ជាមួយនឹងចៅក្រមពេញសិទ្ធិ ៣ រូប ទៀត។

## ហេតុដូច្នេះ សម្រេច

**ចាត់តាំងចៅក្រម Martin Greg KAROPKIN** ជាចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងជំនួសកន្លែងចៅក្រម Jean-Marc LAVERGNE ដែលជាចៅក្រមអន្តរជាតិដែលបានលាលែងពីមុខតំណែងជាចៅក្រមពេញសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក. រហូតដល់ពេលមានការតែងតាំងចៅក្រមពេញសិទ្ធិអន្តរជាតិណាម្នាក់សម្រាប់អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក.។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**និល ណុន**